**BMI0133**

# សម្ភាសន៍ជាមួយឈ្មោះ ឆឹម វ៉ាន់ណៃ ភេទស្រី អាយុ៥៨ឆ្នាំ
# មុខងារជំនាន់ខ្មែរក្រហម “ធ្វើការនៅក្នុងកងចល័ត”
# រស់នៅភូមិប៉ោយក្បៀង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១
# សម្ភាសន៍ដោយៈ ឆាយ ឈុនលី

០១:០២:២១

២៩ទំព័រ

ឈុនលី : ថ្ងៃនេះទី១៥ ខែមិថុនា ហើយខ្ញុំឈ្មោះឈុនលីមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយការងាររបស់ខ្ញុំនឹងធ្វើការស្រាវជ្រាវប្រវត្តិសាស្ត្រនៅសម័យខ្មែរក្រហមដើម្បីចងជាសៀវភៅ ហួស!ខ្ញុំភ្លេចយកសៀវភៅមកជូនអ៊ំ គ្នាខ្ញុំដាក់ឡានយកទៅអស់ហើយ ។ ពួកខ្ញុំយកទៅសរសេរចុះនៅក្នុងសៀវភៅទស្សនាវដ្ដីហ្នឹងណាស ហើយយើងចេញរាល់ខែចែកទូទាំងប្រទេស អ៊ីចឹងហើយបានខ្ញុំចង់សម្ភាសន៍សាច់រឿងអ៊ំដើម្បីក្មេងជំនាន់ក្រោយបានដឹង ហើយខ្ញុំសុំថតសំឡេងអ៊ំព្រោះករណីខ្ញុំកត់អត់ទាន់ចឹងយកទៅសរសេរអត់កើត ។ ដឹងខ្ញុំសុំថតរូបអ៊ីអត់អីទេហ្អីអ៊ំ?

វ៉ាន់ណៃ : ទេ ថតទៅសព្វថ្ងៃគេមានយកទៅអីណាមិនដូចសម័យកាលនោះឯណាត្រូវខ្លាច ។

ឈុនលី : ចា៎!ខ្ញុំត្រូវតែសុំការអនុញ្ញាតិអីអ៊ីចឹងណាសរឿងថតរឿងអី ហើយបើអ៊ំអត់ឲ្យថតទេក៏អត់អីដែរ ។

វ៉ាន់ណៃ : មានទៅអីថតក៏ថតទៅ មិនថតទេក៏ហីទៅកុំថតក៏ល្អផង!

ឈុនលី : អត់មានអីទេគ្រាន់តែយើងដាក់រូបអ៊ំមួយកំណាត់ខ្លួនចឹងទៅហើយយើងសរសេរអត្ថបទឲ្យគេស្គាល់ដឹងថាអ៊ំធ្លាប់ឆ្លងកាត់ដែរអីចឹង ។ អីចឹងខ្ញុំសុំស្គាល់ឈ្មោះអ៊ំម្ដងទៀត ឈ្មោះពេញណាស?

វ៉ាន់ណៃ : ឈ្មោះដាក់នៅក្នុងបញ្ជី ឆឹម វ៉ាន់ណៃ ។

ឈុនលី : ឆឹម វ៉ាន់ណៃ ចុះឈ្មោះគាល ហ្នឹងដាក់ពេលណា?

វ៉ាន់ណៃ : គាល ហ្នឹងគេហៅតាំងពីតូចៗ ។

ឈុនលី : ឈ្មោះហៅទេហ្អី?

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ភ៊ាន់ណៃ ៖ ចាស ហៅគ្រៅ ។

ឈុនលី ៖ អាយុប៉ុន្មានហើយអ៊ំ?

ភ៊ាន់ណៃ ៖ ៩៦!

ឈុនលី ៖ ធីម ភ៊ាន់ណៃ អាយុ៩៦ ភេទស្រី រស់នៅភូមិ?

ភ៊ាន់ណៃ ៖ ភូមិប៉ោយក្មៀង ។

ឈុនលី ៖ ឃុំព្រះនេត្រព្រះ ស្រុកកំណើតអ៊ំនៅឯណា?

ភ៊ាន់ណៃ ៖ នៅនេះឯងប៉ោយក្មៀងនេះឯង ។

ឈុនលី ៖ ទឹកដីនៅហ្នឹងម៉ង?

ភ៊ាន់ណៃ ៖ នៅហ្នឹងតែអាផ្ទះចាស់នៅឯណោះទេដល់បានគ្រួសារ...

ឈុនលី ៖ នៅភូមិអីគេ?

ភ៊ាន់ណៃ ៖ ភូមិប៉ោយក្មៀងដដែលហ្នឹង ។

ឈុនលី ៖ អ៊ំមានបងប្អូនប៉ុន្មាននាក់?

ភ៊ាន់ណៃ ៖ ៦ នាក់ ។

ឈុនលី ៖ ៦ នាក់ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ភ៊ាន់ណៃ ៖ ប្រុសបីស្រីបី ។

ឈុនលី ៖ ប្រុសបីស្រីបី អ៊ំកូនទីប៉ុន្មាន?

ភ៊ាន់ណៃ ៖ កូនពៅគេ ទី៦ ។

ឈុនលី ៖ ចុះកាលមុនសម័យខ្មែរក្រហមហ្នឹងអ៊ំធ្វើអីដូចថាយើងបានរៀនសូត្របានអីទេ??

ភ៊ាន់ណៃ ៖ បានរៀនថ្នាក់ទី៩ ។

ឈុនលី ៖ ទី៩ បានខ្ពស់ដែរតើអ៊ំ?

ភ៊ាន់ណៃ ៖ ខ្ពស់ តែភ្លេចអស់ហើយ ។

ឈុនលី ៖ ឪពុកអ៊ំឈ្មោះអីទៅ?

ភ៊ាន់ណៃ ៖ ធីម សួន ។

ឈុនលី ៖ ម្ដាយ?

ភ៊ាន់ណៃ ៖ ម្ដាយ ថែប ដួន ។

ឈុនលី ៖ ថែប ដួន ។ ចុះអាហ្នឹងឆ្នាំប៉ុន្មានហើយដែលរៀនថ្នាក់ទី៩?

ភ៊ាន់ណៃ ៖ ទេ មិនចាំទេ ។

ឈុនលី ៖ ខ្ទង់៧៨ ៧៩?

វ៉ាន់ណៃ ៖ ៧៨ ៧៩ យើងមិនមាននេះទេ...

ឈុនលី ៖ នៅទីនេះខ្មែរក្រហមចូលមកឆ្នាំណាដែរ?

វ៉ាន់ណៃ ៖ មិនដឹងចូលឆ្នាំណាទេ អត់ចាំទេ ។

ឈុនលី ៖ ចុះអ៊ីដឹងថាមានប្រជាជនថ្មីចូលមកនៅទីនេះឆ្នាំណាដែរ?

វ៉ាន់ណៃ ៖ គេចូលមកនៅក៏អត់បានចាំព្រោះអត់ដែលមកនៅផ្ទះផង ។

ឈុនលី ៖ អាល័យតែទៅណាអ៊ី?

វ៉ាន់ណៃ ៖ ទៅតែធ្វើការ ។

ឈុនលី ៖ ធ្វើការដល់ណា?

វ៉ាន់ណៃ ៖ ដែលអាពត ចូលហើយនោះណាស ទៅច្រើនកន្លែង ។

ឈុនលី ៖ ចុះពេលអាពតចូលមកហ្នឹងអ៊ីនៅផ្ទះចាស់?

វ៉ាន់ណៃ ៖ អត់ទេនៅជើងវត្ត ។

ឈុនលី ៖ ភូមិជើងវត្ត?

វ៉ាន់ណៃ ៖ ភូមិជើងវត្ត?

ឈុនលី ៖ យើងនៅតាំងពីដើមមកហើយអាពតចូលមក ឬក៏អាពតចូលមកជម្លៀសទៅ?

វ៉ាន់ណៃ ៖ អាពតចូលមកជម្លៀសទៅនៅភ្នំកូនដំរីឯណោះ ។

ឈុនលី ៖ ហួស!កាលនោះទៅជាមួយអ្នកណាគេ?

វ៉ាន់ណៃ ៖ ទៅច្រើនណាស់ទាំងភូមិទៅ ។

ឈុនលី ៖ អាហ្នឹងអ៊ីអាចប្រហែលបានទេឆ្នាំណា?

វ៉ាន់ណៃ ៖ ខ្ញុំអត់ចាំទេ ។

ឈុនលី ៖ ដឹងតែពេលនោះខ្មែរក្រហមចូលមក?

វ៉ាន់ណៃ ៖ គេចូលមក គេជម្លៀស ។

ឈុនលី ៖ ជម្លៀសទៅភ្នំកូនដំរី វាជាភូមិឬជាអី?

វ៉ាន់ណៃ ៖ អាហ្នឹងអត់មានភូមិទេ ។

ឈុនលី ៖ ទៅជាមួយប្រជាជនផ្សេងទៀត?

វ៉ាន់ណៃ ៖ ទៅច្រើនណាស់ម៉ាភូមិទាំងអស់គ្នា ។

ឈុនលី ៖ ហើយអ៊ីទៅជាមួយឪពុកម្ដាយ?

ភ៊ាន់ណៃ ៖ ទៅជាមួយឪពុកម្ដាយ ។

ឈុនលី ៖ ហើយទៅដល់គេឲ្យរស់នៅរបៀបម៉េច?

ភ៊ាន់ណៃ ៖ គេឲ្យយើងនៅធ្វើខ្ទមមួយៗម៉ាគ្រួសារ ។

ឈុនលី ៖ ទៅតែភូមិអ៊ីទេ ចុះភូមិផ្សេងទៀត?

ភ៊ាន់ណៃ ៖ ភូមិផ្សេងទៀតក៏គេទៅដែរ ។

ឈុនលី ៖ ហើយទៅដល់គេឲ្យមានកន្លែងនៅ?

ភ៊ាន់ណៃ ៖ មានកន្លែងនៅតើយើងធ្វើខ្លួនយើង យើងដឹកឈើដឹកឫស្សីទៅធ្វើទៅណាស ។

ឈុនលី ៖ ហើយនៅៗជារបៀបគ្រួសារយើងទេ?

ភ៊ាន់ណៃ ៖ គ្រួសារយើង ។

ឈុនលី ៖ អត់មានជារបៀបសហករណ៍ទេ?

ភ៊ាន់ណៃ ៖ នៅទេ ដល់ទៅនៅស្រែះបាន...

ឈុនលី ៖ ចេញពីកូនដីរីទៅនៅស្រែះទៀត?

ភ៊ាន់ណៃ ៖ ទៅនៅស្រែះ ។

ឈុនលី ៖ នៅកូនដីរីបានប៉ុណ្ណាទៅបានទៅនៅស្រែះ?

ភ៊ាន់ណៃ ៖ ខ្ញុំអត់ចាំទេ ចាំតែថាទៅនៅស្រែះ នៅកូនដីរីអត់ចាំទេ ។

ឈុនលី ៖ ប៉ុន្តែនៅបានប្រហែលប៉ុន្មានដែរបានទៅស្រែះ?

ភ៊ាន់ណៃ ៖ នៅមិនយូរទេរួចហើយបានគេឲ្យចេញទៅ ។

ឈុនលី ៖ ច្រេះ?

ភ៊ាន់ណៃ ៖ ស្រែះ ។

ឈុនលី ៖ ស្រែះហ្នឹងអីគេជាភូមិ?

ភ៊ាន់ណៃ ៖ ភូមិ ។

ឈុនលី ៖ ទៅដល់ហ្នឹងធ្វើអីវិញ?

ភ៊ាន់ណៃ ៖ ទៅគេឲ្យធ្វើផ្ទះនៅ ។

ឈុនលី ៖ នៅជាគ្រួសារទៀត?

ភ៊ាន់ណៃ ៖ នៅជាគ្រួសារទៀត ។

ឈុនលី ៖ កាលនោះអ៊ឹងអត់ទាន់មានគ្រួសារទេ?

ភ៊ាន់ណៃ ៖ អត់ទេ ។

ឈុនលី ៖ អាយុប៉ុន្មានអីកាលនោះ?

វ៉ាន់ណៃ ៖ ម្ភៃជាង ២៥ ២៦ ។ ខ្ញុំបានគ្រួសារអាយុ២៨ ។

ឈុនលី ៖ ក្នុងជំនាន់ខ្មែរក្រហមដែរ?

វ៉ាន់ណៃ ៖ អត់ទេ ខ្ញុំបានគ្រួសារប្រហែល២៨ ២៩...

ឈុនលី ៖ ហើយនៅស្រេះធ្វើការអីគេអឺ?

វ៉ាន់ណៃ ៖ ធ្វើការបើអ្នកវ៉ៃយកណ្ដាល់គេឲ្យទៅធ្វើចំការដាំដំឡូងដាំអី ធ្វើស្រែ ។

ឈុនលី ៖ ចុះចំពោះអ៊ីផ្ទាល់អ៊ីធ្វើអី?

វ៉ាន់ណៃ ៖ ខ្ញុំអត់នៅទេ ។

ឈុនលី ៖ ចុះអ៊ីធ្វើអី?

វ៉ាន់ណៃ ៖ ទៅធ្វើការលើកទំនប់ ។

ឈុនលី ៖ លើកទំនប់ដល់ណាទៅ?

វ៉ាន់ណៃ ៖ កាលនោះមិនដឹងដល់ណាទេ ភ្លេចហើយសាមសិបឆ្នាំជាង បើនៅក្នុងភូមិនេះបានចាំបាន នៅក្នុងភូមិខ្ញុំទៅលើកនៅអីកូន...នេះ...

ឈុនលី ៖ មកភូមិហ្នឹងយូរទេ?

វ៉ាន់ណៃ ៖ នៅយូរដែរ ។

ឈុនលី ៖ ប្រហែលប៉ុន្មានដែរអ៊ី? មួយឆ្នាំទេ?

វ៉ាន់ណៃ ៖ ទេ អត់ដល់មួយឆ្នាំទេ មិនបានថាចាប់អារម្មណ៍បើយើងចេះតែខ្លាច ។

ឈុនលី ៖ អាចថាជិតមួយឆ្នាំទេអ៊ី?

វ៉ាន់ណៃ ៖ ចាំ!

ឈុនលី ៖ ជិតមួយឆ្នាំគេជម្លៀសមកវិញ?

វ៉ាន់ណៃ ៖ ជម្លៀសមកវិញ ។

ឈុនលី ៖ មកវិញមកនៅឯណា?

វ៉ាន់ណៃ ៖ មកវិញមកនៅជើងវត្តតែម្ដងអត់មានទៅណាទៀតទេ ។

ឈុនលី ៖ មកនៅក្នុងភូមិហ្នឹងវិញ?

វ៉ាន់ណៃ ៖ ទេ ភូមិជើងវត្ត ។

ឈុនលី ៖ នៅនោះធ្វើអីទៅ?

វ៉ាន់ណៃ ៖ ធ្វើស្រែ អ្នកមានគ្រួសារធ្វើចំការដាំដំឡូង ដាំ...

ឈុនលី ៖ ចុះពេលអ៊ីដល់ស្រុកកំណើតវិញចឹងមើលទៅឃើញសភាពការណ៍យ៉ាងម៉េចដែរ?

វ៉ាន់ណៃ ៖ ហួស!យ៉ាប់ណាស់ អត់មានអីហូបទេ ។

ឈុនលី ៖ អត់អីហូប?

វ៉ាន់ណៃ ៖ អត់ ជួនកាលទៅអត់មាត់ បងក៏គាត់ទៅបូតស្រូវបានហូប ។

ឈុនលី ៖ បងបស់អ៊ីហ្នឹងហ្អី?

វ៉ាន់ណៃ ៖ ហ្នឹងហើយ ។

ឈុនលី ៖ ចុះពេលមក មកទាំងគ្រួសារវិញ?

វ៉ាន់ណៃ ៖ មកទាំងគ្រួសារ ។

ឈុនលី ៖ ចុះគេអីចឹងដែរ?

វ៉ាន់ណៃ ៖ គេក៏គេមកទាំងអស់គ្នាចឹងដែរ ។ គេជម្លៀសយើងមកនៅភូមិដើងវត្តវិញទាំងអស់គ្នា ។

ឈុនលី ៖ ចឹងបានន័យថានៅទីនោះអត់មានអ្នកណានៅទៀតទេ?

វ៉ាន់ណៃ ៖ អត់មានទេដកចេញមកអស់ហើយ ។

ឈុនលី ៖ ចុះម៉េចទៀតទៅអ៊ី?

វ៉ាន់ណៃ ៖ ដល់មកនៅនេះក៏មិនដែលបានមានអីហូបទេ ម៉ែៗនៅនេះគាត់ទៅកិនស្រូវ អ្នកខ្លះទៅចំការទៅគេមានតាមក្រុមតាមកងណាស ។ ក្រុមខ្លះនៅកិនអង្ករក្រុមខ្លះទៅចំការទៅ ពួកក្មេងៗដូចខ្ញុំអីចេះទៅលើកទំនប់ទៅ ។ លើកតំនប់មុនដំបូងខ្ញុំទៅទំនប់ដង្កៀបក្ដាមខាងត្បូងភ្នំលៀប ។

ឈុនលី ៖ ទំនប់ដង្កៀបក្ដាម ខាងត្បូងភ្នំលៀប ។ ភ្នំលៀបហ្នឹងនៅក្នុងឃុំស្រុកអីអ៊ី?

វ៉ាន់ណៃ ៖ ទេ ស្រុកអីទេ!ឃុំភ្នំលៀបក៏មិនដឹងទៅអីកើតចេះទៅ ។

ឈុនលី ៖ ទៅហ្នឹងជាមួយមនុស្សច្រើនហ្អី?

វ៉ាន់ណៃ ៖ ច្រើន នារី យុវជន ។

ឈុនលី ៖ ហើយអ៊ីទៅលើទំនប់នោះធំទេ ទំនប់ភ្នំលៀប?

វ៉ាន់ណៃ ៖ មិនសូវជាធំទេ តូចល្មមទេ ។

ឈុនលី ៖ អ៊ីដឹងទេថាគេលើកទំនប់នោះធ្វើអី?

វ៉ាន់ណៃ ៖ គេថាលើកទំនប់យកទឹកឲ្យយើងលើកទៅយកទឹកធ្វើស្រែ ។ គេឲ្យខ្ញុំលើករួចគេដកទៅកន្លែងផ្សេងទៀតទៅ ។

ឈុនលី ៖ រយៈពេលប៉ុន្មានទៅបានហើយទំបន់ហ្នឹង?

វ៉ាន់ណៃ ៖ អត់ចាំទេអារឿងហើយមិនហើយ ។

ឈុនលី ៖ ចុះពេលអឹចេញពីទំនប់ហ្នឹងមកទំនប់ហ្នឹងហើយឬនៅ?

វ៉ាន់ណៃ ៖ អត់ទាន់ហើយទេ ។

ឈុនលី ៖ ចុះម៉េចបានគេឲ្យយើងចេញមកវិញ?

វ៉ាន់ណៃ ៖ មិនដឹង មិនដឹងផែនការគេយ៉ាងម៉េចទេបានអត់ឲ្យនៅគេដកចេញមក ។

ឈុនលី ៖ ហើយកាលនោះគេចែកយ៉ាងម៉េចអឹ ម្នាក់ធ្វើបានប៉ុណ្ណា?

វ៉ាន់ណៃ ៖ ចែក អានោះយើងធ្វើតាមក្រុមទេមិនសូវយ៉ាប់ទេ គេលើកតាមក្រុមតូចៗសែងគ្នាតិចបាន ។

ឈុនលី ៖ មួយរកុមប៉ុន្មាននាក់ទៅអឹ?

វ៉ាន់ណៃ ៖ ដប់នាក់ ។

ឈុនលី ៖ ហើយមេក្រុមអីដឹកនាំទៅដែរ?

វ៉ាន់ណៃ ៖ មេក្រុមនោះគេអ្នកនៅស្រែះនេះឯង ។

ឈុនលី ៖ រស់នៅទេសព្វថ្ងៃហ្នឹង?

វ៉ាន់ណៃ ៖ មិនដឹងដែរ ។

ឈុនលី ៖ ចុះអ្នកណាមើលការខុសត្រូវនៅភ្នំលៀបហ្នឹង? អ្នកណាគេអ្នកមើលការខុសត្រូវនៅពទំនប់?

វ៉ាន់ណៃ ៖ អត់មានគ្នាខ្ញុំទេ អត់មានអ្នកស្រុកយើងទេពួកគេអ្នកមកពីនោះឯង ។

ឈុនលី ៖ មកពីខាងណាវិញ?

វ៉ាន់ណៃ ៖ មកពីខាង...ដូចគេថាប្រធានកងប្រធានក្រុមមកពីស្រុកនោះឯងដែលពួកនិរតី ។

ឈុនលី ៖ ពួកនិរតីតាកែវ?

វ៉ាន់ណៃ ៖ ចា៎!

ឈុនលី ៖ ចាំឈ្មោះទេអឹ?

វ៉ាន់ណៃ ៖ អត់ចាំទេ មិនចាំឈ្មោះទេព្រោះអីមិនដឹងជាគេដាក់ឈ្មោះដល់តែវាយូរទៅខ្ញុំខ្ជិលចាំក៏ចេះតែភ្លេចៗអស់ទៅ ។

ឈុនលី ៖ ហើយចុះអ្នកណាគេមើលការខុសត្រូវក្នុងភូមិឃុំយើងនេះ?

វ៉ាន់ណៃ ៖ ពីមុន និយាយទៅវានេះ...ដល់នេះទៅគេដក ដាក់មកតាស្ដីទេភ្លេចឈ្មោះបាត់ហើយប្រធានភូមិគេរកនឹកមិនឃើញណាសប្រធានភូមិគេ ។

ឈុនលី ៖ ស្រីឬប្រុសអឺ?

វ៉ាន់ណៃ ៖ ប្រុស ។

ឈុនលី ៖ អ្នកស្រុកហ្នឹងហ្អីដំបូង?

វ៉ាន់ណៃ ៖ អ្នកស្រុកនេះឯងដល់ធ្វើទៅគេដកចេញក៏គេយកគ្នាគេមកដាក់ ។

ឈុនលី ៖ ដកហ្នឹងដកទៅណា?

វ៉ាន់ណៃ ៖ ដកមានទៅណាទេនៅនេះឯង ។

ឈុនលី ៖ គេអត់សំលាប់ទេ?

វ៉ាន់ណៃ ៖ អត់ទេ ។

ឈុនលី ៖ ចុះដល់ពេលចេញមកអឺធ្វើនៅភ្នំលៀបហ្នឹងយូរទេបានចេញមក ។

វ៉ាន់ណៃ ៖ មិនយូរទេប្រហែល១០ងៃអីហ្នឹង មិនបានដាកត់ទុកនោះមិនដឹងទេគ្រាន់តែថាឲ្យទៅធ្វើ មិនដឹងប៉ុន្មានងៃ៎ៗ ។

ឈុនលី ៖ ចុះពេលដកមកចេញទៅកន្លែងណា?

វ៉ាន់ណៃ ៖ ខ្ញុំទៅធ្វើនៅស្ពានរាប ។

ឈុនលី ៖ ស្ពានរាបហ្នឹងនៅឯណា?

វ៉ាន់ណៃ ៖ ស្ពានរាបនៅខាង...ស៊ីងក្រឡាញ់ទៅចេះទៅ ទៅដើងហើយបានបត់ទៅលិចទៅលើកដីដែរ ហ្នឹង ។

ឈុនលី ៖ លើកទំនប់ដែរ?

វ៉ាន់ណៃ ៖ ចា៎!

ឈុនលី ៖ សំបូរទំនប់ណាស់អឺ?

វ៉ាន់ណៃ ៖ សំបូរណាស់តែសព្វថ្ងៃមិនដឹងយ៉ាងម៉េចហើយទេ ។

ឈុនលី ៖ ធ្វើស្រែដែរ?

វ៉ាន់ណៃ ៖ ធ្វើស្រែ ។

ឈុនលី ៖ អាហ្នឹងនៅជិតត្រពាំងថ្មទេ?

វ៉ាន់ណៃ ៖ ត្រពាំងថ្មនៅអីណោះ ស្ពានរាបនៅអីកើត ។

ឈុនលី ៖ ចឹងចេញពីស្ពានរាបបានទៅត្រពាំងថ្មវិញ?

វ៉ាន់ណៃ ៖ ទេ ពីត្រពាំងថ្មរួចទៅអីណាទេ...បកមកផ្ទះបានបន្តិចគេឲ្យទៅទៀតមិនបានសំរាកនៅផ្ទះ បានមួយខែ កន្លះខែទេណានាង មកបានតែ៤ ៥ថ្ងៃគេដកទៅទៀត ។

ឈុនលី : ប៉ុន្តែចង់និយាយថាពេលយើងចេញពីភ្នំលៀបទៅៗ ធ្វើនៅស្ពានរាប?

វ៉ាន់ណៃ : ចា៎!

ឈុនលី : ហើយធ្វើបានប៉ុន្មានបានត្រលប់មកផ្ទះវិញ?

វ៉ាន់ណៃ : ទៅយូរដែរទៅ ។

ឈុនលី : ប្រហែលមួយខែទេ?

វ៉ាន់ណៃ : អត់ដល់ទេ ប្រហែលបួនប្រាំដណ្តប់ថ្ងៃ គិតដកទៅនេះគិតដកទៅនោះ ។

ឈុនលី : ចុះដល់ពេលចេញពីហ្នឹងទៅបានទៅត្រពាំងថ្ម?

វ៉ាន់ណៃ : ដកចេញពីនោះទៅខ្ញុំទៅធ្វើនៅអីនោះទៀត អត់ចាំទេដល់វាដកដាក់កន្លែងច្រើនណាស់ ទៅណេះម្តងទៅណោះម្តងអត់ដែលសួរនៅផ្ទះទេ ។ ដកមកអាទំនប់យើងស្រែះ រន្ទះបាញ់ នេះណាស មកបន្ថែមដី ។

ឈុនលី : ចុះអាត្រង់នោះម៉េចគេហៅរន្ទះបាញ់អីចឹង?

វ៉ាន់ណៃ : វា គេដាក់ឈ្មោះចឹងឯងចេះតែហៅតៗគ្នាទៅ ។

ឈុនលី : ភូមិអីទេហ្អីអាហ្នឹង?

វ៉ាន់ណៃ : អត់មានភូមិអីទេពីមុនៗ គេមានអូរណាសមានអូរមានដៃដល់នេះទៅគេធ្វើទំនប់បណ្តោយ ថ្ងៃមករកភូមិស្រែះ ។ ទៅលើកបានបន្តិចមិនបានឆ្ងាយទេប្រហែលបួនដប់ថ្ងៃក៏ដកទៅ ទៀត ទៅដល់ធ្វើការកន្លែងនោះក៏វាយ៉ាប់ដែរយប់ឡើងចេញទៅ ម៉ោង៤ចេញទៅហើយ ដល់ល្ងិតៗបានមកវិញ ។

ឈុនលី : គ្រប់កន្លែងទាំងអស់ដឹងតែម៉ោង៤ចេញទៅ?

វ៉ាន់ណៃ : ចា៎!ចេញទៅ ។

ឈុនលី : ទៅលើកទំនប់ហ្នឹងពីកន្លែងមួយទៅកន្លែងមួយខុសគ្នាហ្អីរឿងហូបចុក?

វ៉ាន់ណៃ : ខុសគ្នាទាំងអស់ ។

ឈុនលី : យ៉ាងម៉េចទៅអ៊ី?

វ៉ាន់ណៃ : បើពិបាកជាងគេមានតែស្ពានអាត្រពាំងថ្មទេ ពិបាក ។

ឈុនលី : ចឹងបានន័យថាចេញពីអារន្ទះបាញ់ហ្នឹងទៅបានទៅត្រពាំងថ្មបណ្តោយ?

វ៉ាន់ណៃ : នៅព្រៃមាន់ ច្រើនណាស់ព្រៃមាន់នៅច្រូតស្រូវ តែប្រវត្តិខ្ញុំអត់ដែលបាននៅផ្ទះទេ ដើរ រហូត ។

ឈុនលី : ព្រៃមាន់ ច្រូតស្រូវ ។ ហើយទៅណាទៀត?

ភាន់ណៃ ៖ ពីនោះមកច្រូតស្រូវមិនបានប៉ុន្មានថ្ងៃទេប្អូនដប់ថ្ងៃចេញទៅទៀត ។

ឈុនលី ៖ ទៅណា?

ភាន់ណៃ ៖ ច្រើនកន្លែងណាស់មិនដឹងជាទៅកងភ្នំមុន ឬទៅកូន...ត្រពាំងថ្មមុន ។

ឈុនលី ៖ តែភាគច្រើនរយៈពេលខ្លីៗទេ?

ភាន់ណៃ ៖ ចាំ!មិនយូរទេ ។

ឈុនលី ៖ ហើយអ្នកដែលធ្វើការជាមួយអ៊ីហ្នឹងទៅជាមួយគ្នារហូត?

ភាន់ណៃ ៖ ទៅជាមួយគ្នារហូត ។

ឈុនលី ៖ អាហ្នឹងគេហៅកងអីបានចល័តរហូត?

ភាន់ណៃ ៖ កងចល័តពួកនារីយុវជន ។ បើទៅនៅខាងរន្ទះបាញ់នេះគេឲ្យខ្ញុំធ្វើប្រធានក្រុម ខ្ញុំសុំគេអត់ធ្វើទេ ។

ឈុនលី ៖ ម៉េចចឹង?

ភាន់ណៃ ៖ ខ្ជិលធ្វើពិបាកហៅគេទៅធ្វើការចឹងទៅក៏គេមិនឲ្យធ្វើ ។ ម្នាក់ដេកជិតខ្ញុំស្រាប់តែយប់ឡើងបាត់ ។

ឈុនលី ៖ គាត់ឈឺហ្អីយ៉ាងម៉េច?

ភាន់ណៃ ៖ អត់ឈឺទេ ។

ឈុនលី ៖ អាហ្នឹងកាលនៅកន្លែងណា?

ភាន់ណៃ ៖ នៅរន្ទះបាញ់ អត់ឈឺទេស្រាប់តែម៉ោង៤ឡើងចេញទៅធ្វើការទៅស្រាប់ដល់ពេលល្ងាចឡើងយើងហូបបាយ ។ ហូបបាយល្ងាចហើយស្រាប់តែអត់ឃើញវាទេ ចិន បាត់ទៅ ។

ឈុនលី ៖ ស្រី?

ភាន់ណៃ ៖ ស្រី យកទៅវៃចោល ។

ឈុនលី ៖ អាយុប៉ុន្មាន?

ភាន់ណៃ ៖ អាយុម៉ាស្របាលគ្នាហ្នឹងហើយ២២ ២៣ ។

ឈុនលី ៖ ប្រហែលមាននិយាយខុសមាត់ខុសក?

ភាន់ណៃ ៖ វាវាងនេះដែរ ចុះគ្នាចិនមិនចេះធ្វើស្រែឯណាធ្វើទៅគ្នាហត់ ។ មកពីភ្នំពេញមិនដែលស្ទូវក្រទេ ចុះវាស្អាតដល់ចឹងបាត់ទៅ បាត់រហូតមកអីផ្ទះក៏អត់ឃើញ ។

ឈុនលី ៖ ខ្វង់ឆ្នាំណាហើយអ៊ីហ្នឹ?

ភាន់ណៃ ៖ មិនដឹងឆ្នាំណាទេ ។

ឈុនលី ៖ ចេញពីហ្នឹងទៅទៀត?

វ៉ាន់ណៃ ៖ ចេញពីហ្នឹងមកទៅត្រពាំងថ្ម ។

ឈុនលី ៖ ចេញពីហ្នឹងទៅត្រពាំងថ្ម?

វ៉ាន់ណៃ ៖ ចា៎!

ឈុនលី ៖ ប្រហែលជាឆ្នាំណា?

វ៉ាន់ណៃ ៖ អត់ចាំទេរឿងឆ្នាំខ្ញុំអត់ចាំទេ ។

ឈុនលី ៖ រឿងត្រពាំងថ្មអ្នកណាអ្នកគ្រប់គ្រងឲ្យធ្វើ?

វ៉ាន់ណៃ ៖ មិនដឹងមកពីខាងណាទេ ឃើញតែប្រធានកងប្រធានក្រុម ទេសុទ្ធតែពួកនិរតីគេមក ។

ឈុនលី ៖ ចឹងពេលនៅត្រពាំងថ្មហ្នឹងសុទ្ធតែនិរតីហើយ?

វ៉ាន់ណៃ ៖ ចា៎!

ឈុនលី ៖ ចុះកន្លែងផ្សេងៗទៀតដែលទៅហ្នឹងអ្នកណាគ្រប់គ្រង?

វ៉ាន់ណៃ ៖ មានអ្នកនៅស្រែះខ្លះ នៅប៉ោយព្រីងខ្លះ ប៉ោយសំរោង ។

ឈុនលី ៖ ចុះពេលអ៊ំទៅត្រពាំងថ្មហ្នឹងមុនគេហើយហ្នឹអត់ទាន់បានជីកអីទេ?

វ៉ាន់ណៃ ៖ អត់ទាន់មានអ្នកណាជីកអីទេខ្ញុំទៅមុនគេ ។

ឈុនលី ៖ ទៅមុនគេ ហើយចឹងអ្នកគ្រប់គ្រងគឺអ្នកនិរតី?

វ៉ាន់ណៃ ៖ ចា៎!

ឈុនលី ៖ អត់មានចាំឈ្មោះអ្នកណាគេទេ?

វ៉ាន់ណៃ ៖ អត់មានចាំទេ ។

ឈុនលី ៖ ចុះអ៊ំស្គាល់ យាយចែមទេ?

វ៉ាន់ណៃ ៖ ស្គាល់ តែអត់ដែលស្គាល់មុខទេ ។

ឈុនលី ៖ យាយចែម ហ្នឹងគាត់ធ្វើអីកាលនោះ?

វ៉ាន់ណៃ ៖ មិនដឹងជានៅខាងណាទៅខាងណីទេគេថាប្រធានៗចេះតែថាតាមគេទៅ តែមិនដែលឃើញមុខសោះ ។

ឈុនលី ៖ ហើយប្រធានហ្នឹងប្រធានអីគេ?

វ៉ាន់ណៃ ៖ អត់ដឹងទេ មិនហ៊ានសួរគេថាប្រធានអីៗទេ ហើយមកធ្វើនៅព្រៃមាន់នោះក៏ដោយសុទ្ធតែនិរតីពីរបីបួននាក់ ខ្ពស់ ធំ ដឹបងមិនដែលហ៊ានសួរគេទេ ។

ឈុនលី ៖ ចុះអាស៊ីងរាបនេះ?

វ៉ាន់ណៃ ៖ ស្ពានរាបនោះ គាគក់ ខាងគេដែរ ។

ឈុនលី ៖ និរតីដែរ?

វ៉ាន់ណៃ ៖ និរតី ។

ឈុនលី ៖ ចឹងនិរតីសឹងតែទាំងអស់ហើយហ្នឹង?

វ៉ាន់ណៃ ៖ ទេខាងនោះដូចមិនមែននិរតីដូចខាងនោះទេ...មិនមែនទេពួកយើងនេះឯងពួកអ្នកនៅស្រែះ នៅអីនេះ អ្នកស្រែះដងអ្នកដូនប្រែង តែខ្ញុំឃើញគេក៏មិនហ៊ានមើលមុខគេដែរគេថាប្រធានក៏ប្រធានតាមគេទៅខ្លាចចេះតែធ្វើការទៅណាស ។ បើអាត្រពាំងថ្មនេះម្នាក់ពីរម៉ែត្រគឺបកន្ទះរែកណាស ។

ឈុនលី ៖ ម្នាក់?

វ៉ាន់ណៃ ៖ ម្នាក់ណាស ។

ឈុនលី ៖ ចឹងដីបូងគេចាត់ចែងយ៉ាងម៉េចទៅ?

វ៉ាន់ណៃ ៖ គេវាស់ឲ្យមួយក្រុមដប់នាក់ដូចនាងឯងប្រធានក៏កាប់ទៅខ្ញុំរែកទៅណាស់ ។ រែកមុនដីបូងទាបទេចុះយើងដីស្មើចេះរាប ស្រាប់តែទៅដល់ខ្ពស់ ។

ឈុនលី ៖ កំពស់វាប៉ុន្មានទៅ? កំពស់ហ្នឹងគេវាស់ពីបាតទៅលើហ្អី?

វ៉ាន់ណៃ ៖ កំពស់ដែលយើងជីកដីហ្អស?

ឈុនលី ៖ ចាស!

វ៉ាន់ណៃ ៖ យើងវាស់ទៅក្រោមមួយម៉ែត្រទៅ វាស់ទៅចេះពីរម៉ែត្រកន្ទះទៅ ។

ឈុនលី ៖ អាហ្នឹងម្នាក់?

វ៉ាន់ណៃ ៖ ម្នាក់ ។

ឈុនលី ៖ ហើយយកដីហ្នឹងទៅដាក់នៅកន្លែងណា?

វ៉ាន់ណៃ ៖ រែកដាក់ធ្វើទំនប់ណាស ។

ឈុនលី ៖ ដាក់គៀនៗ?

វ៉ាន់ណៃ ៖ ដាក់ដូចយើងដីបូងដូចអាកំបោយគេជីកធ្វើថ្នល់ធ្វើអីចឹងទៅណាស ដូចធ្វើថ្នល់ចឹងរែកទៅចាក់ៗទៅគ្រប់ពីរម៉ែត្រកន្ទះទៅគ្រប់ទៅ បើមិនគ្រប់ក៏យប់ធ្វើទៀតទៅ ។

ឈុនលី ៖ ដីងតែមួយថ្ងៃ?

វ៉ាន់ណៃ ៖ មួយថ្ងៃ ។

ឈុនលី ៖ ហើយអឹធ្វើហើយរហូត?

ភ៉ាន់ណៃ ៖ ទេត្រូវតែប្រឹង បើអត់ប្រឹងវាអត់រួចខ្លួច ហើយកាលនោះមិនដែលបានបាយទេមានតែបបរ ហើយត្រីសាច់មិនដែលមានទេ ប្រហុកទៅ ។ ប្រហុកនោះមើលមិនបានទេស្លឹកឈើស្លឹកព្រៃអីចេះតែបូតទៅសឹងថាមិនបានរស់ដល់សព្វថ្ងៃនេះទេ ។

ឈុនលី ៖ អីចឹងកាលនោះធ្វើការពិបាកហើយហូបចុកអត់គ្រប់ទៀត?

ភ៉ាន់ណៃ ៖ អត់គ្រប់ទេ គ្រប់ដែរតែគ្រប់បបរ ។

ឈុនលី ៖ បានប៉ុន្មាន?

ភ៉ាន់ណៃ ៖ បបរហ្នឹងបានម៉ាកាតូប៉ុណ្ណេះ ពេញម៉ាកាតូ ។

ឈុនលី ៖ កាមែល?

ភ៉ាន់ណៃ ៖ ចា៎ បើថាបបរទៅប្រហែលអន្លរមួយកំប៉ុងហ្នឹងឯង ។

ឈុនលី ៖ ម្នាក់?

ភ៉ាន់ណៃ ៖ ម្នាក់ ។

ឈុនលី ៖ ច្រើនដែរតើហ្នឹមួយកំប៉ុង?

ភ៉ាន់ណៃ ៖ ច្រើន បើនៅក្នុងភូមិបានយ៉ាប់ ខ្ញុំនៅឯណោះហូបបានគ្រប់តែវាបបរណាសអត់មានបានបាយទេ ដួនកាលបានបាយខ្លះទៅ ។

ឈុនលី ៖ គោលបំណងគេដឹកទំនប់ទេមិនមែនអាងទេ?

ភ៉ាន់ណៃ ៖ បញ្ជាឲ្យយើងដឹកហ្នឹងហើយដល់ពេលដឹកទំនប់ទៅយើងដឹកដូចថាយើងដឹកទៅនោះរួច បត់ទៅចេះរួចបត់ទៅចេះទៀតទៅ ទៅដល់កូនខ្វែងអី....

ឈុនលី ៖ មនុស្សប៉ុន្មានរយនាក់ប៉ុន្មានពាន់នាក់ទៅ?

ភ៉ាន់ណៃ ៖ មិនដឹងប៉ុន្មានទេច្រើន មិនដឹងអាណាងាប់អាណារស់ទេ អាណាខុសសីលធម៌អីក៏ងាប់ទៅ ។

ឈុនលី ៖ នៅនឹងកន្លែងហ្នឹង?

ភ៉ាន់ណៃ ៖ អាណាយឺតយ៉ាវក៏ងាប់ខ្លះទៅណាស ។

ឈុនលី ៖ ឃើញផ្ទាល់ភ្នែកម៉ង? ចុះអឺដែលឃើញមានអ្នកកំពុងធ្វើការៗហើយដួលស្លាប់ទេ?

ភ៉ាន់ណៃ ៖ អត់ដែលឃើញទេ ឃើញតែមួយនៅនឹងវត្តនេះវ៉ៃយកណ្តាលស្រលាញ់គ្នាទៅក៏គេវ៉ៃទាំងពីរ ។ គេហៅនារី យុវជនទៅមើលកុំឲ្យយកគំរូតាមយកតំរាប់តាម ។

ឈុនលី ៖ ឈ្មោះអីទៅ?

ភ៉ាន់ណៃ ៖ មិនដឹងឈ្មោះអីមិនដឹងមកពីណាទេ ខ្ញុំទើបនឹងមក...

ឈុនលី ៖ យកទៅដាក់នៅឯណាទៅ?

វ៉ាន់ណៃ ៖ ដាក់នៅផ្សារមុខវត្តនេះ ។

ឈុនលី ៖ អាដើមច័ន្ទក្រាំហ្នឹង?

វ៉ាន់ណៃ ៖ នៅផ្សារព្រែកនេះ បានទៅដល់ទេ?

ឈុនលី ៖ ធ្លាប់ឮគេនិយាយធ្លាប់បានទៅដល់ដែរឃើញមានដើមច័ន្ទក្រាំហើយគេថាចងផ្កាបក្សា...

វ៉ាន់ណៃ ៖ ហ្នឹងឯងចងផ្កាបក្សា នៅនឹងផ្លូវដូចយើងផ្លូវមួយទៅនោះណាស ផ្លូវមួយទៅចេះ ផ្លូវមួយទៀតទៅចេះ អីណេះវត្ត ចងជាប់គ្នាទាំងពីរ ។

ឈុនលី ៖ ពេលនោះអ៊ំធ្វើការនៅអាងហ្នឹ?

វ៉ាន់ណៃ ៖ អត់ទេកាលនោះមិនដឹងខ្ញុំមកពីខាងណាទេ អត់ចាំទេ ។

ឈុនលី ៖ តែអ៊ំបានទៅឃើញនឹងគេដែរហ្ន?

វ៉ាន់ណៃ ៖ ឃើញ ចុះគេហៅទៅនោះ ។

ឈុនលី ៖ គ្នាច្រើនហ្នឹចឹង?

វ៉ាន់ណៃ ៖ ច្រើនម៉ាកងវរៈចឹងគេហៅទៅរបុ៊ំយតំរៀបជួរគ្នាដូចកូនសិស្សតំរង់ជួរគ្នាចេះឯង ។

ឈុនលី ៖ គេថាម៉េចទៅ?

វ៉ាន់ណៃ ៖ គេថាកុមឲ្យនារី យុវជនយកតំរាប់តាម ។

ឈុនលី ៖ ហើយគេស្តីឲ្យទេ គេជេរគេរៀលទេ?

វ៉ាន់ណៃ ៖ គេរៀលគេជេរច្រើនដែរ តែខ្ញុំមិនចាំទេ ។

ឈុនលី ៖ អ្នកណាគេអ្នកជេរ?

វ៉ាន់ណៃ ៖ អត់ចាំមុខទេ ។

ឈុនលី ៖ សុទ្ធតែមេៗទេតើហ្នឹ?

វ៉ាន់ណៃ ៖ មេៗគេ តែមិនមានប្រជាជន ប្រជាជនដែលថាហ្គាស ។

ឈុនលី ៖ ឃើញចឹងភ័យទេ?

វ៉ាន់ណៃ ៖ ភ័យគ្រប់តែគ្នាទៅ ។

ឈុនលី ៖ គេវៃហ្នឹ?

វ៉ាន់ណៃ ៖ វៃណាស ។

ឈុនលី ៖ យកអីគេវៃ?

វ៉ាន់ណៃ ៖ ដំនឹកកាប់ ។

ឈុនលី ៖ អីគេដំនឹកកាប់?

ភ៉ាន់ណៃ ៖ អាចបកាប់យើងនោះណាស អាចបយើងកាប់ ។

ឈុនលី ៖ យកអាហ្នឹងវៃ? ដង យកដងវាវៃហ្អី?

ភ៉ាន់ណៃ ៖ មិនដឹងគេយកដងហ្អីយកអីទេបើគេយារទៅខ្ញុំធ្មេញភ្នែកទៅ ។

ឈុនលី ៖ វៃនៅនឹងមុខ?

ភ៉ាន់ណៃ ៖ វៃនៅនឹងមុខ ។

ឈុនលី ៖ វៃទាល់តែស្លាប់

ភ៉ាន់ណៃ ៖ វៃទាល់តែងាប់ ។ ទំរាំតែងាប់យូរណាស់ កាលនោះដូចជាពូថាពោះធំ ផង...

ឈុនលី ៖ ចា ដូចពូថាពោះធំ ។

ភ៉ាន់ណៃ ៖ ថាពោះធំ! យូរណាស់ទំរាំតែបានងាប់

ឈុនលី ៖ ម៉េចទៀតទៅអ៊ំធ្វើការហ្នឹង?

ភ៉ាន់ណៃ ៖ ធ្វើការនៅត្រពាំងថ្មនោះ?

ឈុនលី ៖ ចា៎!

ភ៉ាន់ណៃ ៖ ខ្ពស់ណាស់ មិនបានជាសួរគេថាប្រធានកងប្រធានក្រុមថាកំពស់អីទេ កំពស់នេះឯងខ្ញុំរែកដាក់ពាក់កណ្តាលហើយបានឡើងទៅលើឡើងពេញហើយបានគេដកឲ្យទៅមួយកន្លែងទៀត ។ នៅទីនោះទឹកសំបូរគ្រាន់ហូបដែរណាស ។

ឈុនលី ៖ ហូបទឹកអីគេ?

ភ៉ាន់ណៃ ៖ ទឹកគេដឹកយកទៅឲ្យ ចុះកាលនោះខែប្រាំងអត់មានទឹកទេណាស គេដឹកយកទៅឲ្យ ។

ឈុនលី ៖ ហើយបាយហូបជាមួយអី ហួស! បបរ?

ភ៉ាន់ណៃ ៖ ប្រហុកណាស គេចំហុយរាវៗចេះតែហូបទៅ ។

ឈុនលី ៖ ឆ្អែតទេអ៊ំ?

ភ៉ាន់ណៃ ៖ ឆ្អែត ឆ្អែតមិនឆ្អែតចេះតែទ្រាំទៅ ។

ឈុនលី ៖ តែចំពោះអ៊ំប៉ុណ្ណឹងឆ្អែតទេ?

ភ៉ាន់ណៃ ៖ ឆ្អែត ។

ឈុនលី ៖ ហើយហូបទឹកហ្នឹងទៅ?

ភ៉ាន់ណៃ ៖ ហូបទឹកទៅ ។

ឈុនលី ៖ ហើយចុះរបៀបម៉េចទៅ?

ភ៉ាន់ណៃ ៖ នៅនោះគេធ្វើពេងឡើងវែងណាសនាង ពេងឡើងវែងហើយដេកទៅ ហើយឥភ៉ាន់យើងក្រវិចអីតិចតួចក៏ស្ពាយទៅ ។ ទៅត្រង់ណាស្ពាយទៅតាមទៅណាស្ពាយតាមទៅណាស ។

ឈុនលី ៖ ធ្វើការតាំងពីម៉ោងប៉ុន្មាន?

ភ៉ាន់ណៃ ៖ ម៉ោង៤ចេញហើយ មើលតែភ្លឺច្បាស់ចេញហើយអត់មានកំណត់ទេតែយើងរួចមកបើមិនរួចនៅទៅ ។

ឈុនលី ៖ ចុហពេលបាយថ្ងៃត្រង់?

ភ៉ាន់ណៃ ៖ បាយថ្ងៃត្រង់មិនដឹងម៉ោងប៉ុន្មានទេ ។

ឈុនលី ៖ ហើយមិនដែលមានបន្លែមមានអីទេ?

ភ៉ាន់ណៃ ៖ កុំថាឡើយបន្លែមនាង!ទឹកក៏ចែកគ្នាដែរ ទឹកមុជក៏អត់ ។

ឈុនលី ៖ អត់មានទឹកមុជទៀត?

ភ៉ាន់ណៃ ៖ អត់មានទេទៅត្រពាំងថ្មអត់មានទឹកមុជទេ ។

ឈុនលី ៖ ចុះរយៈពេលប៉ុន្មានដែលអឹងអត់មុជទឹក?

ភ៉ាន់ណៃ ៖ យូរណាស់ យូរឡើងអាខ្វះឡើងកើតចៃ ។

ឈុនលី ៖ ចុះអ៊ឹកើតទេ?

ភ៉ាន់ណៃ ៖ កើត ។

ឈុនលី ៖ កើតនៅកន្លែងណា ក្បាល?

ភ៉ាន់ណៃ ៖ កើតមិនមានកើតនៅក្បាលទេ ស្រាប់តែខ្ញុំមកពីធ្វើការឃើញរើកៗមួយ ។

ឈុនលី ៖ អត់ដែលមុជទឹក? ហើយទឹកហូបគ្រប់ដែរ?

ភ៉ាន់ណៃ ៖ អត់ទេ ។

ឈុនលី ៖ អីចឹងមិនមានអ្នកឈឺច្រើន?

ភ៉ាន់ណៃ ៖ ទេដូចអត់សូវមានអ្នកឈឺទេ ។

ឈុនលី ៖ គេចែកដីហ្នឹងចែកតាមកំលាំងស្រីប្រុសទេ?

ភ៉ាន់ណៃ ៖ មួយក្រុមយើងដប់នាក់ចឹងក៏យើងធ្វើការដង្ហែគ្នាទៅណាសម្នាក់ពីរម៉ែត្រកន្លះៗ ពីរម៉ែត្រការេ ។

ឈុនលី ៖ អត់មានអ្នកណាបីទេ?

ភ៉ាន់ណៃ ៖ អត់មានទេ មានតែពីរម៉ែត្រការេកន្លះ ។ ខ្ញុំសឹងតែមិនចង់យល់ទេណាសអាពីរម៉ែត្រការេកន្លះហ្នឹងណាសដល់តែទៅកាប់តើបានដឹង ។

ឈុនលី ៖ ធំ?

វ៉ាន់ណៃ ៖ ធំដែរ ។

ឈុនលី ៖ ពីរម៉ែត្រការេកន្លះចឹងមិនត្រូវពីរម៉ែត្រហ្នឹងជំរៅទៅក្រោមដែរ?

វ៉ាន់ណៃ ៖ ទៅក្រោមមួយម៉ែត្រ ។

ឈុនលី ៖ យកតែមួយម៉ែត្រទេ តែអាចេះៗទទឹងបណ្ដោយពីរម៉ែត្រ?

វ៉ាន់ណៃ ៖ អ៊ឺ!

ឈុនលី ៖ ហើយបើដីកអត់ហើយយប់ឡើងបន្ថើយ?

វ៉ាន់ណៃ ៖ ត្រូវតែបន្ថើយឲ្យហើយ ។

ឈុនលី ៖ ចុះអីដែលហើយពីភ្លឺទេ?

វ៉ាន់ណៃ ៖ ហើយពីភ្លឺអត់ដែលដល់យប់ទេ ហើយបក្កីរអត់ចង់បានអាតូចទេក្រួច យកតែអាធំឆាប់រួចខ្លាចឆាប់នោះមិនខំប្រឹងឯណា ។

ឈុនលី ៖ បាក់កំលាំង?

វ៉ាន់ណៃ ៖ បាក់កំលាំង បើយើងថេធ្វីមិនខំថាយើងខ្ជិល ទំរន់ទៅគេវ៉ៃយើងចោលយើងមិនអត់បាននៅដល់សព្វថ្ងៃនេះចឹងយើងទាល់តែខំប្រឹង ។ រួចពីអានោះទៅទៀតទៅកូនខ្វែង កូនខ្វែងបានអត់ទឹកមែនទែន អាកំប៉ុងយើង...

ឈុនលី ៖ កូនខ្វែងហ្នឹងទំនប់មួយផ្សេងទៀត?

វ៉ាន់ណៃ ៖ ទំនប់ជាមួយត្រពាំងថ្មគេបិទអីចេះណាស គេបិតទទឹងថ្ងៃអីចេះរួចដល់ទៅឆ្ងាយចេះទៅបានគេទៅលិចអីចេះទៀត ។ គ្រប់ស្រុកគ្រប់ឃុំណាសទៅលើកបានសព្វថ្ងៃនេះគេទៅលេងទៅអីនោះត្រពាំងថ្ម ។ ទឹកគេស្អាតណាស់នៅដល់សព្វថ្ងៃនេះ ។

ឈុនលី ៖ ចុះត្រពាំងថ្មហ្នឹងបើតាមអ៊ំគិតអត់មនុស្សប្រហែលប៉ុន្មានទៅ?

វ៉ាន់ណៃ ៖ ខ្ញុំអត់ដឹងទេ ។

ឈុនលី ៖ អាចស្មាន បើតាមអ៊ំគិតណាសប្រហែលប៉ុន្មាននាក់ទៅ?

វ៉ាន់ណៃ ៖ អស រាប់ពាន់នាក់ឯណោះមិនមែនតែមួយភូមិយើងនេះអីណា ។

ឈុនលី ៖ ភាគច្រើនអ្នកដែលទៅជីកហ្នឹងនៅឯណា?

វ៉ាន់ណៃ ៖ នៅស្រែះ ស្រមោច នៅពាមអីណាជាមួយគ្នាទាំងអស់អាអ្នកថ្មីអីណាមកពីទីក្រុងភ្នំពេញអីមកពីណោះគេមិនឲ្យនៅជាមួយគ្នាក៏ទៅធ្វើការជាមួយគ្នាដែរ ។

ឈុនលី ៖ អីចឹងអ្នកដែលស្លាប់ច្រើនហ្នឹងភាគច្រើនស្លាប់ដោយសារអី?

ភាន់ណៃ ៖ មិនដឹងស្លាប់ដោយសារស្អីទេ តែកន្ទុំមិនដែលឃើញថាស្លាប់ទេ អត់ដែលនៅម៉ាកងធំ យើងម៉ារយនាក់ ៨០នាក់ទៅអត់ដែលឃើញងាប់ទេ ។

ឈុនលី ៖ ចុះឃើញមានអ្នកផ្សេងទៀតស្លាប់?

ភាន់ណៃ ៖ អ្នកផ្សេងទៀតក៏មិនសូវដែលឃើញទេ មិនដែលបានចេញទៅណាទេណាមីនាង កាប់ដីថា កាប់ពាល់តែរួចមកកន្ទែង ហូបបាយរួចដេក ។

ឈុនលី ៖ ម៉ោងប៉ុន្មានចូលសំរាន្ត?

ភាន់ណៃ ៖ ទេហូបបាយរួច ជួនទៅល្ងិតៗហូបបាយរួចចូលដេកហើយ ។

ឈុនលី ៖ ប្រហែលម៉ោងប៉ុន្មានអឹ?

ភាន់ណៃ ៖ ប្រហែលម៉ោង៩ចូលសំរាក ។

ឈុនលី ៖ ហើយអត់មុជទឹកទៀត?

ភាន់ណៃ ៖ អត់ ។

ឈុនលី ៖ ហើយខោអាវប៉ុន្មានកំប្លេ?

ភាន់ណៃ ៖ ខោអាវអត់មានច្រើនទេ ពីរកំប្លេ បីកំប្លេនឹងឯង

ឈុនលី ៖ ហើយអត់មានអីបោកទៀត?

ភាន់ណៃ ៖ អត់ ជួនកាលទៅក៏មានទឹក បើនៅត្រពាំងថ្មនេះមានទឹកបោកខ្លះបើទៅខាងកូនខ្វែងអត់ មានទឹកដឹកទេ កូនកំប៉ុងប៉ុនណោះ ។

ឈុនលី ៖ ទឹកគេដឹកមកពីណាអឹហ្ន?

ភាន់ណៃ ៖ មិនដឹងមកពីណាទេ ។

ឈុនលី ៖ ចែកឲ្យម្នាក់ប៉ុណ្ណា?

ភាន់ណៃ ៖ ចែកយើងម៉ាកំប៉ុងប៉ុនណោះឯងកំប៉ុង ។

ឈុនលី ៖ សំរាប់ដឹកមួយថ្ងៃ?

ភាន់ណៃ ៖ អត់ដឹកមួយថ្ងៃទេសំរាប់មួយក្រុម១០នាក់ ។

ឈុនលី ៖ បានប៉ុន្មានក្អឹកទេ!

ភាន់ណៃ ៖ ចែកគ្នារកខ្លួនឯងខ្លះទៅណាស ។

ឈុនលី ៖ ដងខ្លួនឯងទឹកស្រែទឹកអីហ្នឹង?

ភាន់ណៃ ៖ ទឹកនៅតាមស្រែ ។

ឈុនលី ៖ អត់រាគអត់អីដែរចឹង?

ភ៉ាន់ណៃ : អត់ដែលរាក អត់មានឈើមានអីទេដែលទៅនៅប៉ុន្មានឆ្នាំហ្នឹង ។

ឈុនលី : អាពេលនៅត្រពាំងថ្មហ្នឹងអ៊ំធ្វើការរយៈពេលប៉ុន្មានដែរ?

ភ៉ាន់ណៃ : យូរណាស់ឡើងរួច ហើយខ្ញុំអត់ដែលថា...

ឈុនលី : ធ្វើឡើងហើយហ្អី?

ភ៉ាន់ណៃ : ឡើងហើយ ។

ឈុនលី : ឡើងហើយឃើញអាងនោះប៉ុនណាទៅ?

ភ៉ាន់ណៃ : ធំ ធំដែរតែមិនដឹង...ចំងាយប៉ុន្មានទេមិនដែលចាប់អារម្មណ៍ថាប្រវែងណាៗទេ

ឈុនលី : តែមកដល់ឥឡូវបើអ៊ំប៉ាន់ប្រមាណមើលប្រហែលប៉ុន្មាន?

ភ៉ាន់ណៃ : ឆ្ងាយដែរអានេះទាល់តែសួរគេអ្នកធ្វើការបានគេដឹងតែខ្ញុំអត់ដែលនេះទេ អស អានេះ ប៉ុន្មានម៉ែត្រៗប៉ុន្មានគីឡូអីទេដឹងតែព្រឹកឡើងទៅកាប់ ក៏កាប់ហើយឡើងមកដេកព្រឹកឡើង ទៅទៀតអត់មានសួរថាប៉ុន្មានម៉ែត្រ ខ្នងប៉ុន្មានអីអត់ទេ ។

ឈុនលី : គោលបំណងគេធ្វើស្រែ?

ភ៉ាន់ណៃ : ទេ ទំនប់នោះមកដល់សព្វថ្ងៃក៏អត់មានធ្វើស្រែអីដែរ ទឹកឡើងជាប់ដល់សព្វថ្ងៃទំនប់នោះ ខ្ពស់ណាស់មីនាង ។

ឈុនលី : ខ្ញុំអត់យល់ អ៊ីចឹងបានន័យថាដីកពីនេះយកទៅដាក់នៅទំនប់?

ភ៉ាន់ណៃ : ចា៎!ធ្វើទំនប់ ។

ឈុនលី : ប្រហែលប៉ុន្មានម៉ែត្រទៅ?

ភ៉ាន់ណៃ : ខ្ពស់ដែរ ខ្ញុំរែកឡើង៦ ៧ម៉ែត្ររែកឡើងទៅលើ ។

ឈុនលី : រែកពីក្រោមហើយឡើងទៅលើទៀត?

ភ៉ាន់ណៃ : ចាស!

ឈុនលី : ចឹងទំនប់ហ្នឹងខ្ពស់ហើយធំទៀត?

ភ៉ាន់ណៃ : ខ្ពស់ ហើយធំ ។

ឈុនលី : វែងទៀត?

ភ៉ាន់ណៃ : វែង មើលទៅឆ្ងាយណាស់មីនាងមើលទៅ២ ៣គីឡូក៏មិនដឹង អាដែងខ្ញុំជីកទទឹងថ្ងៃអីចេះ ព្រឹកឡើងទៅមើលមនុស្សឡើងខ្មៅងងឹតទៅណាស ចុះស្លៀកខ្មៅពាក់ខ្មៅយើងមើលទៅ ឃើញខ្មៅយើងក៏កាប់គេក៏កាប់ កាប់រែកទៅ ។

ឈុនលី : ហើយហ៊ាននិយាយគ្នាទេ?

វ៉ាន់ណៃ ៖ អត់ទេអត់ហ៊ាននិយាយទេ ។

ឈុនលី ៖ អត់និយាយលេងតិចតួចទេ?

វ៉ាន់ណៃ ៖ អត់ អត់មានពេលនិយាយទេ គេខំរបស់គេ យើងខំរបស់យើងទៅឲ្យតែរួច ។

ឈុនលី ៖ ចុះមានគេដើរមើលទេ?

វ៉ាន់ណៃ ៖ មានប្រធានគេ ប្រធានកងគេដើរមើល ។

ឈុនលី ៖ កាចទេ?

វ៉ាន់ណៃ ៖ មិនកាចទេ ។

ឈុនលី ៖ អត់ស្គាល់ឈ្មោះទេប្រធានកង?

វ៉ាន់ណៃ ៖ អត់ស្គាល់ ។

ឈុនលី ៖ អឺដែលឮឈ្មោះតាឡុតទេ?

វ៉ាន់ណៃ ៖ អត់ អត់ដែលឮទេ ។

ឈុនលី ៖ តាឡុតហ្នឹងឮថាគាត់អ្នកមើលការខុសត្រូវដែរ ។

វ៉ាន់ណៃ ៖ អត់ដែលឮទេ ទៅលើកអីណោះឃើញតែប្រធានកង ប្រធានក្រុម ។

ឈុនលី ៖ ចុះពេលធ្វើការហ្នឹងដែលឃើញគេចាប់មនុស្សយកទៅទេ?

វ៉ាន់ណៃ ៖ អត់ដែលទេ ។

ឈុនលី ៖ ឃើញអ្នកឈឺទេ?

វ៉ាន់ណៃ ៖ អត់ ។

ឈុនលី ៖ អត់ដែលឃើញ?

វ៉ាន់ណៃ ៖ អត់ ។

ឈុនលី ៖ ចុះនៅអីចឹងគេមានបែងចែកស្រីប្រុសទេ?

វ៉ាន់ណៃ ៖ ស្រីនៅផ្សេង ប្រុសនៅផ្សេងទៅ ។

ឈុនលី ៖ ចឹងផ្ទះម៉ាល្វែងចឹងទៅនៅមួយក្រុម?

វ៉ាន់ណៃ ៖ ចាស ម៉ាកង ។

ឈុនលី ៖ ម៉ាកងហ្នឹងប៉ុន្មាននាក់?

វ៉ាន់ណៃ ៖ កងច្រើនណាស់ ហាហុកសិបនាក់ ។

ឈុនលី ៖ សុទ្ធតែស្រីៗ?

វ៉ាន់ណៃ ៖ ចាស យើងទៅវែកទៅ បើតិចក៏ស្ពាយទៅ ។

ឈុនលី ៖ ចុះពេលដឹកអាងបណ្ដើហ្នឹងមានភ្លៀងទេ?

ភ៉ាន់ណៃ ៖ អត់ទេ អត់ដែលមានភ្លៀងទេ ។

ឈុនលី ៖ ខែណាទៅ?

ភ៉ាន់ណៃ ៖ មិនដឹងទេ ខ្ញុំអត់ដែលចាំទេមិនដឹងថាខែណាៗទេគេឲ្យទៅធ្វើការក៏ចេះតែទៅហើយ ធ្វើការមិនដែលមកផ្ទះទេ មកតែបួនប្រាំថ្ងៃគេឲ្យមកវិញ ។

ឈុនលី ៖ តែគ្រាន់តែថាទៅនោះមានទឹកហូប រយៈពេលប៉ុន្មានបានគេឲ្យទៅកូនខ្វែង?

ភ៉ាន់ណៃ ៖ យូរដែរ ។

ឈុនលី ៖ ដល់ឆ្នាំទេអ៊ី?

ភ៉ាន់ណៃ ៖ មិនដល់ឆ្នាំទេ ខ្ញុំអត់ដែលរាប់ថ្ងៃតែគេថារួចហ្នឹងក៏ទៅៗ ។

ឈុនលី ៖ រួចហ្នឹងរួចទាំងអស់គ្នា?

ភ៉ាន់ណៃ ៖ រួចក៏ទៅទាំងអស់ណាសរួចក៏ដក់ទៅល្បឹនទៅធ្វើកន្លែងផ្សេង ។

ឈុនលី ៖ ទៅកូនខ្វែង អាហ្នឹងរបៀបទំនប់ម្ខាងទៀតហ្អី?

ភ៉ាន់ណៃ ៖ ទំនប់ជាប់គ្នាហ្នឹងកាច់ជ្រុង ។

ឈុនលី ៖ នៅទីនោះមានអូរមានអីឬយ៉ាងម៉េចបានជាគេធ្វើទំនប់?

ភ៉ាន់ណៃ ៖ អត់ទេមិនដឹងគេធ្វើអីៗអត់ដឹងទេគេឲ្យបិទ ស្រាប់តែដល់សព្វថ្ងៃនេះទឹកវាមកច្រើនពេញប្រៀបកំពស់ប្រហែលប្រាំប្រាំមួយម៉ែត្រពេញអស់ទៅក៏ទឹកវាពេញដែរ ។ គេធ្វើទុកធ្វើស្រែធ្វើអីគេអាខាងក្រោមគេទុកធ្វើស្រែ ។

ឈុនលី ៖ បើតាមគិតទៅគេចាប់ធ្វើពីឆ្នាំណាមក ៧៦ ៧៧?

ភ៉ាន់ណៃ ៖ មិនដឹងជាឆ្នាំណាទេ អត់ចាំបានទេ ។

ឈុនលី ៖ ហើយទៅកូនខ្វែងហ្នឹងពិបាកម៉េចខ្លះទៅអ៊ី?

ភ៉ាន់ណៃ ៖ ទៅនោះលើកទាបជាងត្រពាំងថ្ម ទៅកូនខ្វែងលើកវាទាបជាង ទៅក៏ឲ្យយើងលើកពីរនាក់ពីរម៉ែត្រគីបកន្ទះ ។

ឈុនលី ៖ ម្នាក់ពីរម៉ែត្រគីបកន្ទះទៀតហើយ?

ភ៉ាន់ណៃ ៖ ចាស!

ឈុនលី ៖ តែនៅទីនោះតូចជាង? ហូបអីទៅអ៊ី?

ភ៉ាន់ណៃ ៖ ហូបបបរ ហើយជួនទៅក៏បាយ ។

ឈុនលី ៖ ហើយអត់មានទឹកហូបទៀត?

ភ៉ាន់ណៃ : អត់ទឹកហូបដែលគេមាន គេនៅភូមិគេមានជីកអណ្តូងដល់ទឹកនោះវាខះទៅវាមានទឹកចេញ តិចៗក៏គេមានឡានដឹងយកមកឲ្យបានទៅចែកគ្នាម្នាក់មួយកំប៉ុងចឹងទៅ ។

ឈុនលី : អីចឹងកាលនៅត្រពាំងថ្មអត់ដែលមុជទឹកដល់ទៅកូនខ្វែងអត់ទៀត?

ភ៉ាន់ណៃ : អត់ទៀត ។

ឈុនលី : ប្រហែលជាប៉ុន្មានខែប៉ុន្មានឆ្នាំទៅអ៊ឹ ចូលដល់ឆ្នាំទេ?

ភ៉ាន់ណៃ : មិនដល់ឆ្នាំទេ វាមិនដល់ឆ្នាំទេ ដល់មកវិញបានទៅមុជទឹកនៅព្រៃមាន់ទៅដល់រួចទៅ ។

ឈុនលី : ហេតុអីបានមកវិញ?

ភ៉ាន់ណៃ : រួច!

ឈុនលី : អីចឹងបានន័យថាពេលអ៊ឹចេញមកហ្នឹងត្រពាំងថ្មក៏ហើយ នៅកូនខ្វែងក៏ហើយ?

ភ៉ាន់ណៃ : ហើយ!

ឈុនលី : អីចឹងមើលទៅមិនល្ហឹងល្ហើយហើយ?

ភ៉ាន់ណៃ : ល្ហឹងល្ហើយ ។

ឈុនលី : ហើយអត់មានទឹកទេកាលនោះ?

ភ៉ាន់ណៃ : អត់ ។

ឈុនលី : អត់មានភ្លៀងទេ?

ភ៉ាន់ណៃ : កាលនោះខែប្រាំង ។

ឈុនលី : ខ្ញុំឮគេថានៅទីនោះមានមនុស្សស្លាប់ច្រើនណាស់អ៊ឹ?

ភ៉ាន់ណៃ : ច្រើន តែនៅតាមកងខ្ញុំអត់មានស្លាប់ទេ ។

ឈុនលី : តែបើតាមអ៊ឹដឹងស្លាប់ច្រើនដោយសារអីគេ?

ភ៉ាន់ណៃ : មិនដឹងស្លាប់ដោយសារអី ចុះដែលគ្នាធ្វើការវាសោវាអីទៅបើធ្វើការរាល់ថ្ងៃនោះ តែកន្លែងខ្ញុំអត់ដែលបាត់ទេ នៅទាំងអស់ ។

ឈុនលី : តែភាគច្រើនគេយកវ័យកណ្តាល?

ភ៉ាន់ណៃ : អត់មានវ័យកណ្តាលទេ គេកយកតែយុវជន ។

ឈុនលី : ប្រហែលខ្ទង់ម្ភៃជាងហ្នឹអត់មានចាស់ទេ?

ភ៉ាន់ណៃ : អត់មានចាស់ទេយកតែក្មេងៗ ។

ឈុនលី : ត្រឹមអាយុសាមសែអីអត់មានទេ?

ភ៉ាន់ណៃ : អត់មានទេ មានតែនារីយុវជនទេតែអ្នកមានប្តីមានប្រពន្ធអីធ្វើការនៅតាមភូមិ ។

ឈុនលី ៖ នៅកូនខ្វែងហ្នឹងប្រហែលប៉ុន្មានបានមកវិញ?

វ៉ាន់ណៃ ៖ ទាល់តែរួចទំបន់នោះ ។

ឈុនលី ៖ អត់ដឹងរយៈពេលទេ? មកវិញនៅឯណា?

វ៉ាន់ណៃ ៖ មកវិញក៏មកនៅភូមិបានបួនប្រាំថ្ងៃគេឲ្យចេញទៅទៀតទៅ ចេញពីភូមិដើនវត្តទៅនៅភូមិដើនវត្តវិញ ។

ឈុនលី ៖ រួចយើងទៅណាទៀត?

វ៉ាន់ណៃ ៖ មកវិញគេឲ្យទៅកងវ៉ា ។

ឈុនលី ៖ កងវ៉ាហ្នឹងអីគេ?

វ៉ាន់ណៃ ៖ កងវ៉ាអីភ្នំស្វាយទៅអីដើងសេរីសោភ័ណ្ឌទៅធ្វើចំការកប្បាស ។

ឈុនលី ៖ ទៅហ្នឹងជាមួយកងដដែល?

វ៉ាន់ណៃ ៖ កងដដែលប៉ុន្តែដកចេញខ្លះហើយ អាខ្លះនៅផ្ទះ អាខ្លះក៏រត់អីទៅណាស ។ អាខ្លះរត់គេចមកផ្ទះវិញថាឈឺថាអីទៅអត់បានទៅ ។ ទៅតិច ទៅបេះកប្បាស ។

ឈុនលី ៖ ចុះកាលទៅនោះមានទឹកមានអីប្រើទេ?

វ៉ាន់ណៃ ៖ មានទឹកបបូរ ។

ឈុនលី ៖ ទឹកអីគេប្រើហ្នឹង?

វ៉ាន់ណៃ ៖ ទឹកស្រះយើងហ្នឹង ។

ឈុនលី ៖ ហូបចុកអីម៉េចដែរ?

វ៉ាន់ណៃ ៖ ហូបបាយ គេឲ្យយើងហូបបាយ ។ ខ្ញុំទៅធ្វើការបានបួនដប់ថ្ងៃខ្ញុំរត់មកផ្ទះ ។

ឈុនលី ៖ លួចរត់?

វ៉ាន់ណៃ ៖ លួចរត់ ។

ឈុនលី ៖ អត់ខ្លាចទេ?

វ៉ាន់ណៃ ៖ អត់ខ្លាច ។

ឈុនលី ៖ ម៉េចបានរត់មកផ្ទះ?

វ៉ាន់ណៃ ៖ លួចរត់ ខ្ញុំទៅនៅព្រៃមាន់ក៏រត់មកផ្ទះដែរ ដល់ទៅនៅកងវ៉ានោះខ្ញុំរត់មកពីរនាក់មីមួយនោះនៅខាងដើង ។ រត់មកមីនោះទាប មកខែវស្សាផងមកដេកតាមវាល ឆ្លងទឹកឆ្លងទំនប់ ឆ្លងទឹកតាមបៀតស្ពានជ្រៅណាសនាងទឹកឡើងលេចក្បាល មកអត់ខ្លាចថាងាប់ទេហែល...

ឈុនលី ៈ តែម្នាក់ឯងទេ?

ភ៉ាន់ណៃ ៈ ពីរនាក់ ហែលអូសមីមួយនោះមកផង មកដល់ភ្នំជញ្ជាំងនេះក៏...

ឈុនលី ៈ ភ្នំជញ្ជាំង?

ភ៉ាន់ណៃ ៈ ភ្នំជញ្ជាំងនៅជប់ ខាងលិចជប់ ដើរមកទាំងយប់លុះដល់ភ្លឺច្បាស់មកក៏ដើរមកក៏គេកាក់ៗ ដល់គេកាក់ដល់ប្រាប់គេទៅ ទៅផ្ទះបានតែពីរបីថ្ងៃក៏មកវិញទៅៗ

ឈុនលី ៈ ទៅវិញហ្អី?

ភ៉ាន់ណៃ ៈ ទៅវិញៗ

ឈុនលី ៈ ដល់ទៅវិញគេរករឿងដែរអត់?

ភ៉ាន់ណៃ ៈ អត់អីទេ ឈប់ទៅៗ

ឈុនលី ៈ ចុះគេអត់សួរនាំទេ?

ភ៉ាន់ណៃ ៈ អត់ទេ ដល់បាត់ទៅក៏ហីទៅដល់នេះទៅក៏បញ្ជូនទៅវិញទៅៗ ដល់ចប់ពីនោះទៅ ទៅទៀត ទៅឆ្ងាយណាស់ដល់សុភីអីណោះៗ

ឈុនលី ៈ ហេតុអីបានអីលួចរត់មក នឹកផ្ទះហ្អី?

ភ៉ាន់ណៃ ៈ នឹកផ្ទះៗ

ឈុនលី ៈ ហត់ពេក?

ភ៉ាន់ណៃ ៈ ហត់ពេក បើអត់បានសំរាកអីម៉ាថ្ងៃៗ

ឈុនលី ៈ ហើយទៅវិញធ្វើអីទៀត?

ភ៉ាន់ណៃ ៈ ទៅចំការកប្បាស ទៅបាញ់ថ្នាំបាញ់អីៗ

ឈុនលី ៈ ហូបបបរ?

ភ៉ាន់ណៃ ៈ ហូបបាយៗ យើងនៅចេះតែខ្វាច...

ឈុនលី ៈ ខ្វាអីគេ?

ភ៉ាន់ណៃ ៈ ខ្វាចខ្មោចខ្វាចអី ដល់នៅទៅខ្ញុំយកដំនឹកដាក់ឈរអីចេះទៅក៏វាមុតជើង មុតជើងតូចញ៉ិប ដល់មុតជើងតូចញ៉ិបចេះទៅក៏ហើម វាហើយជើងត្រូវថ្នាំបាញ់កប្បាសនោះ ដល់វាហើម គេថាតែខ្ញុំងាប់ទេតើៗ

ឈុនលី ៈ កន្លែងណាមុតហ្នឹង?

ភ៉ាន់ណៃ ៈ នេះមេជើងនេះ...

ឈុនលី ៈ ចុះម៉េចបានហើមអីហើមអីចឹង?

វ៉ាន់ណៃ ៖ ចុះវាជាតិថ្នាំពុលនោះ ដីវាមានជាតិថ្នាំពុកលដល់យើងវាដាច់សាច់បន្តិចទៅវាចូលអាជាតិថ្នាំពុលហើយហើម ។

ឈុនលី ៖ បាញ់ថ្នាំហ្នឹងសំលាប់ដង្កូវហ្អី?

វ៉ាន់ណៃ ៖ ថ្នាំសំលាប់សត្វល្អិត បាញ់ដង្កូវគេថាតែខ្ញុំងាប់ហើយ ។ ដែរ អាបងនៅភូមិជាមួយគ្នាថាវាងាប់ហើយថាទៅរកមើលវា តែមិនបានមើលទេថាងាប់បាត់ហើយតែមិនដឹងទៅរកឯណា ។ ថាឈ្មោះខ្ញុំហ្នឹងឯងងាប់ដល់ពីរបីថ្ងៃក្រោយមកខ្ញុំនាំគ្នាទៅលេងផ្ទះគាត់ ។ ហ៊ឺស! អញថាតែងាប់ហើយ ខ្ញុំថាទៅងាប់អីងាយៗនៅតស៊ូចាល់តែបានរស់ ។

ឈុនលី ៖ គិតទៅជំនាន់នោះគេបាញ់ថ្នាំគេប្រើឧបករណ៍អីគេខ្លះ?

វ៉ាន់ណៃ ៖ ប្រើធុងដូចយើងសព្វថ្ងៃនេះ ធុងថ្នាំដូចយើងបាញ់ថ្នាំកាដីបថ្នាំអីហ្នឹង

ឈុនលី ៖ ចុះមានរុំច្រមុះរំអីទេ?

វ៉ាន់ណៃ ៖ អត់ទេ?

ឈុនលី ៖ អីចឹងមិនពុលហើយ?

វ៉ាន់ណៃ ៖ មិនដឹងពុលឬមិនពុលបើខ្ញុំមិនដែលទៅផង ខ្ញុំមិនដែលបានទៅបាញ់ថ្នាំបាញ់អីផងខ្ញុំទៅតែឃើញគេបេះកប្បាសបេះអីចឹង ។

ឈុនលី ៖ បេះកប្បាសយូរទៀតទេអ៊ឺ?

វ៉ាន់ណៃ ៖ មិនយូរទេទៅបានតែមួយខែទេដឹងគេដកទៅកន្លែងផ្សេងទៀតទៅ ។ ទៅអីសុភីណោះ ។

ឈុនលី ៖ ធ្វើអីគេនៅនោះ?

វ៉ាន់ណៃ ៖ ទៅបានតែប៉ុន្មានក៏បកមកវិញទៅតែដើរអត់មានបានជិះឡានជិះអីទេមីនាង ។

ឈុនលី ៖ ស្ទូង ដក?

វ៉ាន់ណៃ ៖ ទៅច្រូត ច្រូតស្រូវខ្លះទៅ ។

ឈុនលី ៖ យូរទេអ៊ឺ?

វ៉ាន់ណៃ ៖ ទេ ទៅកាលនោះមិនយូរទេទៅមិនសូវយូរទេ ឆាប់បានមកវិញ ។ ទៅកាលនោះមិនដឹងទៅធ្វើអីផងទេ ទៅច្រូតស្រូវ ធ្វើអានេះតិច អានោះតិច ជីកដីខ្លះអីខ្លះទៅណាស ។

ឈុនលី ៖ ចុះអ៊ឹការឆ្នាំណា?

វ៉ាន់ណៃ ៖ ការឆ្នាំណាទេ ។

ឈុនលី ៖ បែកអាពតហើយនៅ?

វ៉ាន់ណៃ ៖ អាពតវាទៅអស់ហើយ ។

ឈុនលី ៖ ចុះអាពេលវៀតណាមចូលមកហ្នឹងអ៊ីនៅឯណា?

វ៉ាន់ណៃ ៖ វៀតណាមចូលមកហ្នឹងខ្ញុំនៅតែអីដើមវត្តនេះឯង ដល់តែវាទាំគ្នាទៅអស់ហើយម៉ែឪនាំគ្នាមកនៅភូមិ មកនៅផ្ទះខ្លួនឯង ។

ឈុនលី ៖ ចុះអាពេលវៀតណាមចូលមកហ្នឹងមានរញ៉េរញ៉ៃអីទេ?

វ៉ាន់ណៃ ៖ អត់មានអីទេ ។

ឈុនលី ៖ មានបាញ់គ្នាដែរអត់?

វ៉ាន់ណៃ ៖ អត់ទេ អត់មានអីទេ ។

ឈុនលី ៖ រត់ចេញអស់ហ្អី?

វ៉ាន់ណៃ ៖ វាចេញទៅអស់ ។

ឈុនលី ៖ ចុះមានប្រជាជនយើងរត់ទៅតាមអាពតទេ?

វ៉ាន់ណៃ ៖ មានទៅតាមម្នាក់ដែរ តែសព្វថ្ងៃដាច់បាត់ហើយ ។

ឈុនលី ៖ ម៉េចក៏ទៅតែម្នាក់អីចឹង?

វ៉ាន់ណៃ ៖ មិនដឹងជាយ៉ាងម៉េចទេ វាទៅធ្វើការជាមួយគេក៏...

ឈុនលី ៖ ធ្វើនិរសារទេដឹង?

វ៉ាន់ណៃ ៖ មិនដឹង វាមានប្រពន្ធក៏មិនដឹង ។

ឈុនលី ៖ ចាំទេអ៊ីកាលនោះវៀតណាមចូលឆ្នាំណា?

វ៉ាន់ណៃ ៖ មិនដឹងជាឆ្នាំណាទេ ៧៩ក៏មិនដឹង?

ឈុនលី ៖ ៧៩ តែអត់ដឹងខែណាបើនៅភ្នំពេញខែ១ ។

វ៉ាន់ណៃ ៖ បែបដូចតែគ្នាហ្នឹង!

ឈុនលី ៖ ខែ១ ក្រែងលនៅទីនេះយូរជាង ។

វ៉ាន់ណៃ ៖ គេចូលមកថ្ងៃជាមួយគ្នាហ្នឹងដល់គេទៅអស់ទៅយើងក៏ចូលស្រុក ។

ឈុនលី ៖ អ្នកស្រុកអ្នកភូមិសប្បាយចិត្តទេកាលនោះ?

វ៉ាន់ណៃ ៖ សប្បាយដែរបានវាទៅអស់ទៅអរ ។

ឈុនលី ៖ ហើយយើងនាំគ្នានៅជុំគ្នា?

វ៉ាន់ណៃ ៖ មកនៅជុំ ។

ឈុនលី ៖ ចុះអ៊ីការពេលណាចោះ?

វ៉ាន់ណៃ ៖ ការដូចជាការឆ្នាំប៉ុន្មានទេ ដល់សព្វថ្ងៃនេះវា២៨ឆ្នាំហើយ...

ឈុនលី ៖ ពីជំនាន់នោះមកសាមសិបឆ្នាំហើយ តាំងពីវៀតណាមចូលឆ្នាំ៧៩ ៣២ឆ្នាំហើយ ។ អីចឹងវៀតណាមចូលមកយូរទេបានអីការ?

វ៉ាន់ណៃ ៖ យូរដែរ ។

ឈុនលី ៖ ចុះម៉េចបានអីស្គាល់អ៊ីប្រុស?

វ៉ាន់ណៃ ៖ អត់ស្គាល់ទេ គាត់នៅភ្នំតូចភ្នំធំឯណោះ ។

ឈុនលី ៖ ភ្នំតូចភ្នំធំនៅនៅឯណា?

វ៉ាន់ណៃ ៖ នៅខាងត្បូង ផ្លូវយើងជិះឡានមកពីភ្នំពេញហ្នឹង ។

ឈុនលី ៖ ដំរីស កូនដំរីហ្នឹងហ្អី?

វ៉ាន់ណៃ ៖ ទេ អាភ្នំច្រើន ភ្នំតូចភ្នំធំនៅខាងលិចផ្លូវនោះនៅឯណុងឯង ។

ឈុនលី ៖ ចុះចេញពីអាពតមកអ៊ីធ្វើអីគេ?

វ៉ាន់ណៃ ៖ ទេ ដល់ចប់អាពតទៅអត់មានអីទេចាំមើលតែបងប្អូនមកជុំគ្នា នៅឡើងត្នោតឡើងអីចឹងទៅ គាត់ឡើងត្នោត ។

ឈុនលី ៖ ចុះធ្វើម៉េចបានស្គាល់អ៊ី?

វ៉ាន់ណៃ ៖ អត់ស្គាល់ទេ គាត់មកនៅក្នុងភូមិមានៅអាផ្លូវទៅត្រង់ចេះទៅយកមកនៅជាមួយគ្នា ហើយគាត់ក៏រកស៊ី រកអង្ករកអីលក់ទៅ ។

ឈុនលី ៖ ចុះក្រោយមកអីការហើយអ៊ីនៅឯណា?

វ៉ាន់ណៃ ៖ ការហើយនៅឯណោះភូមិប៉ោយក្មៀង តែនៅឯក្នុងដល់ការបានពីរឆ្នាំបានកូនមួយបាន គាត់ទៅណោះ ។ មកនេះតែនៅដីគេ ដល់នេះក៏ម្ចាស់គេសុំក៏ចែកឲ្យគេខ្លះទៅណាស ។

ឈុនលី ៖ ម្ចាស់គេរបៀបថានៅតាំងពីមុនខ្មែរក្រហមហ្អី?

វ៉ាន់ណៃ ៖ អត់ទេ ម្ចាស់គេពីកំណើត បងប្អូនណាស គាត់សុំក៏ចែកគាត់ខ្លះទៅណាស ។

ឈុនលី ៖ ហើយឡូវបានកូនចៅប៉ុន្មាននាក់ហើយអ៊ី?

វ៉ាន់ណៃ ៖ កូនឡើង៧នាក់ ។

ឈុនលី ៖ ៧នាក់ ស្រីប៉ុន្មានប្រុសប៉ុន្មានទៅ?

វ៉ាន់ណៃ ៖ ស្រី២ប្រុស៥ ។

ឈុនលី ៖ ហើយក្រោយមកអ៊ីខស្បានិយាយរឿងរ៉ាវប្រាប់កូនដែរ?

វ៉ាន់ណៃ ៖ និយាយប្រាប់ដែរតើ តែកូនគេទៅរៀនបានសៀវភៅបានអី ។

ឈុនលី ៖ សៀវភៅអីគេ?

ភ៉ាន់ណៃ ៖ សៀវភៅយើងអាសម័យនោះ ។

ឈុនលី ៖ ពណ៌ខ្មៅហ្នឹងហ្អី?

ភ៉ាន់ណៃ ៖ ចាស!

ឈុនលី ៖ បានមកពីណាវិញ?

ភ៉ាន់ណៃ ៖ គ្រូចែក!

ឈុនលី ៖ ពួកខ្ញុំមកចែកលើកមុនទេដឹង អង្គការខ្ញុំមកចែក ។

ភ៉ាន់ណៃ ៖ ណុងទេដឹង!

ឈុនលី ៖ អាកាលវឹកមកសម្ភោធផ្លូវណាស?

ភ៉ាន់ណៃ ៖ ចាស!

ឈុនលី ៖ ចុះពីមុនៗដែលអ៊ំនិយាយរឿងប្រាប់កូនចៅមុនពេលបានសៀវភៅហ្នឹងជឿដែរ?

ភ៉ាន់ណៃ ៖ វាជឿ!

ឈុនលី ៖ ជឿ!ហើយចុះខុសប្លាស្តូរនាំអ៊ំដែរ?

ភ៉ាន់ណៃ ៖ វាអត់ដែលសួរផង!

ឈុនលី ៖ អត់ដែលសួរថាប្រវត្តិម៉ែឯងយ៉ាងម៉េចអី?

ភ៉ាន់ណៃ ៖ អត់ដែលសួរផង ។

ឈុនលី ៖ ចុះភាគច្រើនអ៊ំនិយាយប្រាប់?

ភ៉ាន់ណៃ ៖ និយាយប្រាប់!

ឈុនលី ៖ ប្រាប់ពេលណាទៅ?

ភ៉ាន់ណៃ ៖ ប្រាប់ថា នែ!បើយើងសព្វថ្ងៃនេះស្រួលណាស់ បើម៉ែបីឆ្នាំយ៉ាប់ណាស់មិនស្រួលទេដើរតែរែក ដើរយប់ដើរថ្ងៃទំរាំដល់កន្លែងធ្វើការម៉ាកន្លែងៗ វាជឿ ។

ឈុនលី ៖ ចុះអ៊ំដែលឮថាមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ភ៉ាន់ណៃ ៖ ទេ កាលលើកមុនមីប្អូនខ្ញុំបានទៅដល់កន្លែងនោះដែរ ។

ឈុនលី ៖ ទៅភ្នំពេញហ្នឹង?

ភ៉ាន់ណៃ ៖ ចាស!

ឈុនលី ៖ គាត់ឈ្មោះអី?

ភ៉ាន់ណៃ ៖ ឈ្មោះ ម៉ាលី ។

ឈុនលី ៖ ហ្អស!ម៉ាលី?

វ៉ាន់ណៃ : ចាស គេទៅអបជាមួយអ្នកធ្វើការដែរ ប្រធាន ។

ឈុនលី : ទៅជាមួយពួហ៊ុយទេដឹង?

វ៉ាន់ណៃ : ចាស!

ឈុនលី : ទៅជួបជាមួយពួកខ្ញុំហើយចឹង គាត់ឈ្មោះអ៊ីម៉ាលី?

វ៉ាន់ណៃ : ទេ មិនដឹងត្រកូលស្អីទេ?

ឈុនលី : បងប្អូនបង្កើតហ្អី

វ៉ាន់ណៃ : អត់ទេ សាច់ញាតិ សាច់ញាតិតែខាងម៉ែទេវាដាច់ឆ្ងាយគ្នាហើយ ។

ឈុនលី : ចុះដល់ពេលទៅចឹងមកវិញគាត់និយាយប្រាប់ទេ?

វ៉ាន់ណៃ : និយាយប្រាប់តើ ទៅហ្នឹងនិយាយប្រាប់ចង់យមដងចង់អីដងដែលវាកំសត់ពេក ពិបាក ពេកកាលជំនាន់បីឆ្នាំ ។

ឈុនលី : ចុះអ៊ឹអត់ដែលពួតាមពក៏មានទេ តាមវ៉ាត់យូ?

វ៉ាន់ណៃ : មិនដែលបាន អត់មានផង ។

ឈុនលី : សព្វថ្ងៃហ្នឹងគេកំពុងតែកាត់ទោសមេដឹកនាំខ្មែរក្រហមមាន នួន ជា អៀង សារី អៀង ធីរិទ្ធ ខៀវ សំផន ហើយតាឌុច សាច់រឿងគាត់ទាក់ទងហ្នឹងទួលស្លែងអីចឹងម៉ាសំណុំរឿង របស់គេណាសដល់ម៉ារឿងទៀតមាន៤នាក់ នួន ជា អៀង សារី អៀង ធីរិទ្ធ ខៀវ សំផនហើយខែ៦ហ្នឹងគេចាប់ផ្តើមបើកសាវនាការលើសំណុំរឿងគាត់ណាស ។ តាឌុច ហ្នឹងគេកាត់ទោសហើយៗជិតសំរេចហើយ ។ កាលលើកមុនគេកាត់ទោសម្តងហើយៗ កាលឆ្នាំ២០១០គេចេញសេចក្តីសំរេចមកគេឃុំគាត់៣៥ឆ្នាំ ប៉ុន្តែដោយសារគេកាត់កុះ នៅសល់១៩ឆ្នាំ ហើយឥឡូវគាត់ប្តឹងទៅថ្នាក់លើទៀត ប្តឹងបន្តទៀត ហើយអត់ទាន់ ចេញជាលទ្ធផលទៀតទេ ។ ដល់ពេលបួននាក់ទៀតគេទើបតែរៀចចំសាវនាកាគាត់ខែ៦ ហ្នឹង ។ អីចឹងអ៊ឹទើបតែដឹងឬដឹងយូរហើយ?

វ៉ាន់ណៃ : ដឹងយូរហើយ!

ឈុនលី : ពេលដឹងអីចឹងមានអារម្មណ៍យ៉ាងម៉េចដែរ?

វ៉ាន់ណៃ : មានអារម្មណ៍យ៉ាងម៉េចបើនឹកឃើញតែកាលនោះថាវាពិបាកប៉ុណ្ណា ។

ឈុនលី : អ៊ឹសប្បាយចិត្តទេពេលដែលមានតុលាការកាត់ទោស?

វ៉ាន់ណៃ : សប្បាយចិត្តណាស់បានគេកាត់ទោសអីចឹងនោះ ។

ឈុនលី ៖ ប៉ុន្តែពួកគាត់ចាស់ៗអស់ហើយអ៊ំ ចឹងអ៊ំគិតថាគួរតែកាត់ទោសគាត់ដែរអត់បើគាត់ចាស់ៗ អស់ហើយ?

វ៉ាន់ណៃ ៖ អត់ដឹងដែរ ស្រេចតែខាងតុលាការគេកាត់ទៅ កាត់យ៉ាងម៉េចក៏កាត់ទៅ។ បើកាត់អីចឹង ខ្ញុំក៏យល់ស្របដែរ។

ឈុនលី ៖ អ៊ំយល់ស្របឲ្យមានការកាត់ទោសទោះបីជាគាត់ចាស់ក៏ដោយ?

វ៉ាន់ណៃ ៖ ចាស់ក៏ដោយ ស្រេចតែអ្នកធ្វើការទេ។

ឈុនលី ៖ ចុះអ៊ំអត់ខ្លាចគាត់ស្លាប់ក្នុងគុកទេ?

វ៉ាន់ណៃ ៖ មិនដឹងដែរស្លាប់មិនស្លាប់អ្នកណាដឹង។

ឈុនលី ៖ ចឹងអ៊ំមានអីចង់បន្ថែមទេ?

វ៉ាន់ណៃ ៖ អត់ទេ!

ឈុនលី ៖ អរគុណអ៊ំច្រើន។

«ចប់»